# 4 សិទ្ធិ និងយុត្តិធម៌ផ្នែកបរិស្ថាន

**នៅក្នុងជំពូកនេះ :** **ទំព័រ**


មហន្តរាយឧស្ម័នពុលនៅក្រុងបូប៉ាល់ . . . . . . . . . . . . . . . . . . . . . . . . . . . 36
ការតស៊ូទាមទារសិទ្ធិនិងយុត្តិធម៌ . . . . . . . . . . . . . . . . . . . . . . . . . . . . . 37
តើសារធាតុពុលអាចចូលក្នុងខ្លួនយើងដោយរបៀបណា . . . . . . . . . . . . . . . . . . 40
គ្លីនិកសុខភាពមួយដែលបង្កើតឡើងដើម្បីការពារបរិស្ថាន . . . . . . . . . . . . . . . . 40
ការធ្វើការងារដើម្បីការផ្លាស់ប្តូរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . 42
ការប្រឈមគ្រោះថ្នាក់ដែលអាចទទួលបាន? ដើម្បីអ្នកណា? . . . . . . . . . . . . . . . . 43

# សិទ្ធិ និងយុត្តិធម៌ផ្នែកបរិស្ថាន



មនុស្សគ្រប់រូបនៅក្នុងសហគមន៍នានា មានសិទ្ធិទទួលបាននូវសុខភាពល្អ និងបរិស្ថានល្អប្រសើរនិងដែលមានសុវត្ថិភាព។ ជាអកុសល សិទ្ធិទាំងនេះច្រើនតែមិនមានការគោរពទេ។ មនុស្សជាច្រើនរងគ្រោះដោយសារបញ្ហាសុខភាពធ្ងន់ធ្ងរដែលបង្កឡើងដោយការខ្វះខាតនូវតម្រូវការចាំបាច់ និងភាពលើសលុបនៃសារធាតុគ្រោះថ្នាក់។ មនុស្សដែលងាយរងគ្រោះបំផុត គឺអ្នកដែលមានឋានៈទាប ដោយសារពូជសាសន៍ ជាតិពន្ធុ សាសនា ភេទ វណ្ណៈ ភាពក្រីក្រ ឬមូលហេតុដទៃទៀត។ ជាទូទៅពួកគេទាំងនេះរងគ្រោះមុនគេ និងធ្ងន់ធ្ងរជាងគេ។

ការតស៊ូដើម្បីរស់នៅក្នុងបរិស្ថានល្អប្រសើរ មានសុវត្ថិភាព ផលិតភាព និងភាពសប្បាយរីករាយ ពីសំណាក់សហគមន៍ទាំងឡាយដែលសិទ្ធិរបស់ខ្លួនមិនទទួលបានការគោរពពីក្រុមអ្នកមានអំណាច ជួនកាលគេហៅថា ការតស៊ូទាមទារយុត្តិធម៌ផ្នែកបរិស្ថាន។

នៅជុំវិញពិភពលោកមានសាច់រឿងជាច្រើននិយាយអំពីសហគមន៍ផ្សេងៗដែលបានរងគ្រោះដោយមិនសមហេតុផលពីមហន្តរាយនៃសុខភាពបរិស្ថាន ក៏ដូចជាសាច់រឿងជាច្រើនដែលនិយាយអំពីការរៀបចំសកម្មភាពផ្សេងៗរបស់ប្រជាជនដើម្បីការពារសិទ្ធិរបស់ខ្លួនក្នុងការទទួលបានសុខភាពល្អនិងយុត្តិធម៌ផ្នែកបរិស្ថាន ក្នុងពេលដែលគ្រោះមហន្តរាយបានចាប់ផ្តើម។ ជំពូកនេះនឹងនិយាយពីសាច់រឿងទាំងនេះ។

# មហន្តរាយឧស្ម័នពុលនៅក្រុងបូប៉ាល់

នៅយប់ថ្ងៃទី3 ខែធ្នូ ឆ្នាំ1984 ក្នុងទីក្រុងបូប៉ាល់នៃប្រទេសឥណ្ឌា មហន្តរាយដ៏គួរឲ្យរន្ធត់មួយបានកើតឡើង។ រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិតដែលស្ថិតតំបន់ប្រជាជនក្រីក្រកុះករ នៅក្បែរទីក្រុងបូប៉ាល់ បានលេចធ្លាយឧស្ម័នពុលជាច្រើនតោនទៅក្នុងខ្យល់។ ប្រព័ន្ធផ្តល់សញ្ញាអាសន្នរបស់រោងចក្រត្រូវបានបិទ ដូច្នេះសហគមន៍នេះមិនបានឮការប្រកាសអាសន្នអ្វីឡើយ។

អ្នករស់រានពីគ្រោះមហន្តរាយម្នាក់ឈ្មោះថា អាហ្សីហ្សា ស៊ុលតង់ នៅចាំថា ៖




អ្នករស់រានម្នាក់ទៀតឈ្មោះថា ចំប៉ាទេវីសុខឡា នៅចាំថា ៖




ឧស្ម័នពុលបានសម្លាប់មនុស្សជាច្រើននាយប់នោះ។ ៣ថ្ងៃក្រោយមក មនុស្សប្រហែល៨.០០០នាក់បានបាត់បង់ជីវិត។ ប៉ុន្តែនេះមិនមែនជាចុងបញ្ចប់នៃគ្រោះមហន្តរាយទេ។ ជាការពិត មហន្តរាយទើបតែចាប់ផ្តើមប៉ុណ្ណោះ។

ជាង២០ឆ្នាំក្រោយមក មនុស្សជាង២០.០០០នាក់បានស្លាប់ដោយសារសារធាតុពុលដែលនៅសល់ក្នុងខ្លួនរបស់ពួកគេ។ មនុស្សជាច្រើនទៀតមានជំងឺធ្ងន់ធ្ងរ ដូចជាពិបាកដង្ហើម និងដកដង្ហើមឈឺចាប់, ក្អកជាប្រចាំ, គ្រុនក្តៅ, បាត់បង់ញាណដឹងនៅដៃជើង, ខ្សោយ, ភ័យខ្លាច, ធ្លាក់ទឹកចិត្ត, និង**ជំងឺមហារីក**។ កូនៗ និងចៅៗរបស់អ្នកដែលនៅរស់រាន បានរងគ្រោះពី**ពិការភាពពីកំណើត**យ៉ាងធ្ងន់ធ្ងរ ដូចជាស្វិតអវៈយវៈ, ការលូតលាស់យឺតយ៉ាវ, និងបញ្ហាប្រព័ន្ធបន្តពូជ និងប្រព័ន្ធសរសៃប្រសាទជាច្រើនទៀត។ ក្នុងទីក្រុងបូប៉ាល់មានមនុស្សជាង១៥០.០០០នាក់បានរងគ្រោះថ្នាក់ដោយសារឧស្ម័នពុលដែលធ្លាយក្នុងយប់នោះ។

# ការតស៊ូទាមទារសិទ្ធិនិងយុត្តិធម៌

រហូតមកដល់សព្វថ្ងៃនេះ កន្លែងដែលធ្លាយឧស្ម័នពុលមិនទាន់មានការសម្អាតនៅឡើយទេ ហើយរោងចក្រដែលត្រូវបានបោះបង់ចោល នៅតែធ្វើឲ្យប្រជាជននឹកឃើញពីមហន្តរាយនេះនៅឡើយ។ គំនរសារធាតុគីមីពុលនៅតែស្ថិតក្នុងខ្យល់ដដែល ហើយទឹកក្នុងដីនៅខាងក្រោមទីក្រុងនេះ ត្រូវបានបំពុល។ មនុស្សជាច្រើនមិនដែលទទួលបានការព្យាបាលចាំបាច់លើបញ្ហាសុខភាពរបស់ខ្លួនទេ។ ដោយមូលហេតុទាំងនេះហើយ ទើបប្រជាជនក្នុងទីក្រុងបូប៉ាល់មិនគិតថាគ្រោះមហន្តរាយនេះជាអ្វីដែលកើតឡើងតែក្នុងអតីតកាលប៉ុណ្ណោះទេ។ ពួកគេមើលឃើញថា វាគឺជាមហន្តរាយដែលកើតឡើងជាបន្តដែលពួកគេត្រូវប្រឈមមុខរាល់ថ្ងៃ។

រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិតនេះជាកម្មសិទ្ធិរបស់**សាជីវកម្មពហុជាតិ**មួយ (ក្រុមហ៊ុនធំមួយដែលធ្វើការនៅក្នុងប្រទេសជាច្រើន) ដែលមានឈ្មោះថា យូញៀនខាបៃត៍ (Union Carbide)។ អ្នកនៅរស់រានពីមហន្តរាយ ដឹងថាវាពិតជាមិនត្រឹមត្រូវទេដែលជីវិតរបស់ពួកគេរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីមហន្តរាយបែបនេះ។ អ្នកដែលរងផលប៉ះពាល់មិនមានប្រាក់ដើម្បីព្យាបាលជំងឺរបស់ខ្លួន ឬថែទាំសមាជិកគ្រួសាររបស់ខ្លួនដែលមិនអាចធ្វើការងារទៀតបាន។ ពួកគេចង់ឲ្យក្រុមហ៊ុនទទួលខុសត្រូវលើបញ្ហានេះ។ ប៉ុន្តែក្រុមហ៊ុនយូញៀនខាបៃត៍បាននិយាយថា មហន្តរាយនោះបង្កឡើងដោយកម្មករម្នាក់នៅក្នុងរោងចក្រ ហើយបដិសេធមិនទទួលខុសត្រូវអ្វីទាំងអស់។

ក៏ដូចជាប្រជាជនដទៃទៀតដែលតស៊ូទាមទារសិទ្ធិនិងយុត្តិធម៌ដែរ ប្រជាជនដែលរងការប៉ះពាល់ពីមហន្តរាយក្នុងទីក្រុងបូប៉ាល់ បានដឹងថាភាពក្រីក្ររបស់ពួកគេមិនត្រឹមតែធ្វើឲ្យបញ្ហារបស់ពួកគេកាន់តែអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាផ្នែកដ៏ធំមួយនៃមូលហេតុដែលមហន្តរាយនេះកើតឡើង។



# ហេតុអ្វីមហន្តរាយកើតឡើង?

មហន្តរាយក្រុងបូប៉ាល់គឺជាហេតុការណ៍ដ៏គួរឲ្យរន្ធត់មួយដែលមិនគួរកើតឡើងទាល់តែសោះ។ ប៉ុន្តែទោះបីវាគួរឲ្យរន្ធត់យ៉ាងណាក៏ដោយ វាក៏មិនគួរឲ្យភ្ញាក់ផ្អើលដែរ។ សកម្មភាព "ប៉ុន្តែហេតុអ្វី...?" អាចជួយឲ្យយល់អំពីមូលហេតុឫសគល់នៃមហន្តរាយក្រុងបូប៉ាល់។




នៅទូទាំងពិភពលោក សាជីវកម្មបានសាងសង់រោងចក្រដែលបំពុលបរិស្ថាន កាកសំណល់ពុល និងគម្រោងឧស្សាហកម្មដទៃទៀតដែលមានគ្រោះថ្នាក់ នៅក្នុងតំបន់ប្រជាជនដែលមានការគៀបសង្កត់បំផុតពីភាពក្រីក្រ និងឋានៈទាប។ តាមរបៀបនេះ ប្រទេសនិងសហគមន៍ក្រីក្រក្លាយទៅជាកន្លែងចោលសារធាតុពុល។ ហេតុដូច្នេះហើយបានជាការការពារសុខភាពបរិស្ថាន មិនមែនត្រឹមតែជាបញ្ហាដែលយើងត្រូវផ្លាស់ប្តូរផលិតផលប្រើប្រាស់ និងវិធីបោះវាចោលប៉ុណ្ណោះទេ ប៉ុន្តែវាជាបញ្ហាដែលយើងត្រូវបញ្ជាក់អំពីការរំលោភអំណាចពីសំណាក់អ្នកមានអំណាច និងអំពីការប៉ះពាល់សុខភាពលើអ្នកងាយរងគ្រោះបំផុត។



# យុទ្ធនាការអន្តរជាតិដើម្បីយុត្តិធម៌សម្រាប់ក្រុងបូប៉ាល់




អ្នករស់រានពីការធ្លាយឧស្ម័នក្នុងក្រុងបូប៉ាល់ បានធ្វើការជាមួយគ្នាដើម្បីទាញចំណាប់អារម្មណ៍មកលើទុក្ខវេទនារបស់ខ្លួន និងដើម្បីឲ្យក្រុមហ៊ុនព្រមទទួលខុសត្រូវ។ ពួកគេបានរៀបចំបាតុកម្មអត់អាហារ និងមិនព្រមហូបរហូតទាល់តែអាជ្ញាធរឮពីការទាមទាររបស់ខ្លួន។ ពួកគេបានដើរដង្ហែរក្បួនចម្ងាយ៧៥០គីឡូម៉ែត្រ ដោយគ្មានអាហារនិងទឹក ទៅកាន់ទីក្រុង។ ពួកគេក៏បានដើរទៅរដ្ឋធានីផងដែរដើម្បីទាមទារយុត្តិធម៌។ ពួកស្ត្រីបានបោះតង់នៅខាងមុខការិយាល័យរបស់ចៅហ្វាយក្រុង។ ពួកគេបោះតង់នៅទីនោះរយៈពេល៣ខែ។ រៀងរាល់ថ្ងៃ តាំងពីព្រលឹមទល់ព្រលប់ ពួកគេស្រែកទាមទារយុត្តិធម៌របស់ខ្លួន។

ច្រើនឆ្នាំបន្ទាប់ពីគ្រោះមហន្តរាយ តុលាការបានបញ្ជាឲ្យសាជីវកម្មយូញៀនខាបៃត៍ បង់ប្រាក់ចំនួន៤៧០លានដុល្លាអាមេរិកទៅឲ្យរដ្ឋាភិបាលឥណ្ឌា។ នេះគឺជាជ័យជំនះដ៏សំខាន់មួយ ប៉ុន្តែវាមិនគ្រប់គ្រាន់ទេ។ ភាគច្រើននៃប្រាក់ទាំងនោះមិនបានដល់ដៃអ្នករស់រានពីមហន្តរាយនោះទេ។

បន្ទាប់មក យូញៀនខាបៃត៍ត្រូវបានលក់ទៅឲ្យសាជីវកម្មពហុជាតិមួយទៀតហៅថា ដូវឃែមីខល (Dow Chemical)។ ក្រុមហ៊ុនដូវឃែមីខល ក៏បដិសេធមិនទទួលខុសត្រូវ ឬជួយប្រជាជនដែលរងគ្រោះឲ្យទទួលការព្យាបាលដែរ។ ទាំងរដ្ឋាភិបាលឥណ្ឌានិងរដ្ឋាភិបាលសហរដ្ឋអាមេរិក សុទ្ធតែគ្មានឆន្ទៈក្នុងការនាំយកមន្ត្រីជាន់ខ្ពស់ដែលទទួលខុសត្រូវលើមហន្តរាយនោះ មកទទួលទោសឡើយ។

អ្នករស់រានទាំងនោះបានរៀបចំយុទ្ធនាការអន្តរជាតិមួយ ដើម្បីបន្តការតស៊ូទាមទារយុត្តិធម៌របស់ខ្លួន។ ពួកគេបានគៀងគរការគាំទ្រពីសំណាក់សិស្សនិស្សិត ក្រុមអ្នកបរិស្ថាន និងអង្គការសិទ្ធិមនុស្សនានា។ ដោយមានការគាំទ្រពីមនុស្សនៅទូទាំងពិភពលោក អ្នករស់រានក្នុងក្រុងបូប៉ាល់បានបញ្ជូនសំណើរទាមទារយុត្តិធម៌របស់ខ្លួនទៅទីស្នាក់ការធំរបស់ក្រុមហ៊ុនយូញៀនខាបៃត៍ និងក្រុមហ៊ុនដូវឃែមីខល។ អ្នករស់រានទាំងនេះបានជំរុញទឹកចិត្តអ្នកដទៃឲ្យបន្តបាតុកម្មអត់អាហារ និងធ្វើសកម្មភាពផ្សេងៗដើម្បីទាញចំណាប់អារម្មណ៍លើទុក្ខវេទនារបស់ពួកគេ។ នៅទីបំផុតពួកគេបានជួយទ្រទ្រង់គ្រួសាររបស់ខ្លួន, រៀបចំការថែទាំសុខភាពដោយខ្លួនឯង (មើលទំព័រ345), ជួយគាំទ្រជនរងគ្រោះនៃមហន្តរាយសារធាតុពុលផ្សេងៗទៀត, និងបន្តរស់រានរហូតមក។

ពាក្យស្លោកដែលពួកគេប្រើនៅក្នុងយុទ្ធនាការយុត្តិធម៌ក្រុងបូប៉ាល់គឺ "គ្មានម្តងទៀតឡើយនៅក្រុងបូប៉ាល់!"។ គោលដៅរបស់ពួកគេគឺដើម្បីបង្ការគ្រោះមហន្តរាយបរិស្ថានស្រដៀងគ្នានេះ កុំឲ្យកើតឡើងនៅពេលអនាគតទៀត។ តាមរយៈការតស៊ូជាអន្តរជាតិ ពួកគេបានបង្រៀនមនុស្សនៅទូទាំងពិភពលោកនូវមេរៀនដ៏សំខាន់ស្តីពីផលប៉ះពាល់យូរអង្វែងនៃការប្រឈមនឹងសារធាតុពុល។ អ្នករស់រានក្នុងក្រុងបូប៉ាល់បានបង្ហាញថា គ្រោះថ្នាក់ពីឧស្សាហកម្មអាចកើតឡើងគ្រប់ពេល ហើយប្រជាជនក្រីក្រគឺជាអ្នករងការប៉ះពាល់ធ្ងន់ធ្ងរជាងគេ។ ការតស៊ូទាមទារសិទ្ធិនិងយុត្តិធម៌របស់ពួកគេ បានក្លាយជាគំរូដល់អ្នករៀបចំសហគមន៍ទាំងឡាយនៅក្នុងពិភពលោក។

# តើសារធាតុពុលអាចចូលក្នុងខ្លួនយើងដោយរបៀបណា



ការបរិភោគនិងផឹក
(លេប)



ការដកដង្ហើម
(ស្រូប)

និង



តាមស្បែក
(ជ្រាប)

កាលណាមនុស្សម្នាក់ប្រឈមនឹង(ប៉ះពាល់ដោយផ្ទាល់)សារធាតុគីមីពុលកាន់តែយូរ នោះវាអាចបង្កគ្រោះថ្នាក់កាន់តែខ្លាំង។ ក្នុងក្រុងបូប៉ាល់ ប្រជាជនរាប់ពាន់នាក់បានប្រឈមនឹងឧស្ម័នមួយរំពេច ដោយការដកដង្ហើមចូលនិងការជ្រាបចូលតាមស្បែក។ នេះគឺជាមហន្តរាយបន្ទាន់។ ដោយសារសារធាតុគីមីមិនត្រូវបានសម្អាត ហើយវាសាយភាយយ៉ាងឆ្ងាយពាសពេញតំបន់ដែលនៅជុំវិញរោងចក្រ, ទើបសារធាតុពុលបានចូលទៅក្នុងដីនិងទឹកក្នុងដី។ ច្រើនឆ្នាំរហូតមកដល់សព្វថ្ងៃ ប្រជាជនកំពុងផឹកទឹកដែលមានសារធាតុពុលទាំងនេះ។ នេះគឺជាផ្នែកមួយនៃមហន្តរាយយូរអង្វែង។

ទោះបីការប្រឈមនឹងសារធាតុពុលមានទ្រង់ទ្រាយធំដូចក្នុងក្រុងបូប៉ាល់ ឬក៏ជាការប្រឈមដ៏សាមញ្ញដូចជាសារធាតុពុលក្នុងថ្នាំលាប ទឹករំលាយវត្ថុផ្សេងៗ ឬផលិតផលធម្មតាដទៃទៀតក៏ដោយ, កិច្ចការដំបូងដែលអ្នកត្រូវធ្វើ គឺនៅឲ្យឆ្ងាយពីសារធាតុគីមី ឬយកវាចេញឲ្យឆ្ងាយពីអ្នក ដើម្បីកុំឲ្យមានការប្រឈមតទៅទៀត។ បន្ទាប់មកត្រូវបង្ការការប្រឈមក្នុងពេលអនាគតថែមទៀត។ (សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាសុខភាពបណ្តាលមកពីសារធាតុគីមីពុល សូមមើលជំពូកទី16)។

## គ្លីនិកសុខភាពមួយដែលបង្កើតឡើងដើម្បីការពារបរិស្ថាន

ប្រជាជនក្នុងក្រុងបូប៉ាល់កំពុងតែតស៊ូដើម្បីយុត្តិធម៌ផ្នែកបរិស្ថាន។ ក្នុងពេលជាមួយគ្នា ពួកគេកំពុងព្យាយាមព្យាបាលពីមហន្តរាយ។ អ្នករស់រានពីមហន្តរាយនិងអ្នកស្ម័គ្រចិត្តដទៃទៀតបានបង្កើតគ្លីនិកមួយឈ្មោះថា សំបាវណា(Sambhavna) ដើម្បីផ្តល់ការថែទាំសុខភាពដល់សហគមន៍ទាំងមូល ដោយមិនប្រកាន់ថាមានលទ្ធភាពបង់ប្រាក់ឬអត់ មានសាសនាឬវណ្ណៈខុសៗគ្នាក៏ដោយ។ *Sambhavna* មានន័យថា "លទ្ធភាព" ជាភាសាសំស្ក្រឹត(Sanskrit) និងភាសាហិណ្ឌី(Hindi)។

គ្លីនិកសំបាវណា គឺជាគំរូនៃសុខភាពបរិស្ថាន។ វាត្រូវបានបង្កើតនិងដំណើរការឲ្យមានសុវត្ថិភាព និង ស្ថិរភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន។ ឧទាហរណ៍ ៖

- មានតែទឹកក្តៅនិងសាប៊ូប៉ុណ្ណោះដែលត្រូវបានប្រើក្នុងការសម្អាតគ្លីនិក ដើម្បីធានាថាគ្មាននរណាម្នាក់រងគ្រោះថ្នាក់ដោយសារសារធាតុពុលក្នុងផលិតផលសម្អាតឡើយ។
- បុគ្គលិកគ្លីនិកបានសាងសង់សួនដំណាំមួយដើម្បីដាំរុក្ខជាតិឱសថ។ សារធាតុគីមីមិនត្រូវបានប្រើក្នុងសួនដំណាំនេះទេ។ ប្រជាជនដែលទទួលការព្យាបាលនៅគ្លីនិក ធ្វើការនៅសួនដំណាំ និងដកយកដើមថ្នាំរបស់ខ្លួនដើម្បីយកទៅព្យាបាល។
- នៅពេលត្រូវការអាគារគ្លីនិកថ្មីៗ មានតែសម្ភារៈសំណង់ដែលគ្មានសារធាតុពុលប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់។ អាគារទាំងនោះប្រើប្រាស់សម្ភារៈក្នុងស្រុក ហើយត្រូវបានសាងសង់ឡើងដោយឲ្យពន្លឺនិងខ្យល់ធម្មជាតិចេញចូលបាន។
- ទឹកភ្លៀងត្រូវបានត្រងទុកពីដំបូលក្បឿងក្នុងរដូវវស្សា រួចរក្សាទុកក្នុងអាងសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំង។
- ទឹកដែលប្រើសម្រាប់បោកគក់ ត្រូវបានបង្ហូរទៅក្នុងត្រពាំងមួយ បន្ទាប់មកវាត្រូវបានយកទៅស្រោចដី និងសួនរុក្ខជាតិឱសថ។
- អគ្គិសនីត្រូវបានផលិតដោយ**បន្ទះស្រូបពន្លឺព្រះអាទិត្យ**ដែលបង្កការបំពុលបរិស្ថានតិចតួចបំផុត។



គ្លីនិកសំបាវណាបានបង្ហាញអំពីមធ្យោបាយក្នុងការសម្រេចបាននូវសុខភាពសម្រាប់មនុស្សគ្រប់គ្នាដោយមិនព្យាបាលតែជំងឺទេ ប៉ុន្តែគឺបង្ការជំងឺតាំងពីដំបូង។ ឧទាហរណ៍របស់ពួកគេក្នុងការកាត់បន្ថយគ្រោះថ្នាក់ពីសារធាតុពុល អាចត្រូវបានយកមកអនុវត្តតាម នៅក្នុងសាលារៀន, ក្រុមហ៊ុន, ការិយាល័យរដ្ឋាភិបាល, និងផ្ទះរបស់យើង។ ប៉ុន្តែទោះបីយើងខំកែប្រែផ្ទះនិងស្ថាប័នរបស់យើងឲ្យមានសុខភាពល្អប្រសើរនិងកាន់តែមានស្ថិរភាពយ៉ាងណាក៏ដោយ, យើងគ្រប់គ្នា ជាពិសេសអ្នកងាយរងគ្រោះបំផុត នៅតែស្ថិតក្នុងការប្រឈមគ្រោះថ្នាក់ដដែល ដរាបណាឧស្សាហកម្មនៅតែបន្តផលិត និងប្រើប្រាស់សារធាតុពុលនោះ។ (សម្រាប់ព័ត៌មានបន្ថែមអំពីគ្លីនិកសំបាវណា សូមមើលទំព័រ345)។

# ការធ្វើការងារដើម្បីការផ្លាស់ប្តូរ

តាមរយៈការចាត់ចែងសហគមន៍របស់ពួកគេ ឲ្យតស៊ូដើម្បីសុខភាពនិងសុខុមាលភាពយូរអង្វែង, អ្នករស់រានពីមហន្តរាយក្រុងបូប៉ាល់បានជំរុញទឹកចិត្តមនុស្សនៅជុំវិញពិភពលោក ឲ្យធ្វើសកម្មភាពផ្សេងៗដើម្បីសិទ្ធិនិងយុត្តិធម៌ផ្នែកបរិស្ថាន។ គោលការណ៍នៃការចាត់ចែងដើម្បីកាត់បន្ថយគ្រោះថ្នាក់ពីសារធាតុគីមីពុល បានបង្ហាញថាមានប្រយោជន៍ ៖

- **ជៀសវាងសារធាតុពុលក្នុងជីវិតប្រចាំថ្ងៃ។** ប្រើប្រាស់សារធាតុគីមីមិនពុល សម្រាប់ការលាងសម្អាតនៅផ្ទះ, នៅស្ថាប័នក្នុងសហគមន៍, ឬនៅកន្លែងធ្វើការ( មើលទំព័រ372 ទៅ374 )។ មិនប្រើថ្នាំសម្លាប់សត្វល្អិត ឬជីគីមី នៅក្នុងសួនដំណាំ, បរិភោគអាហារដែលគ្មានជាតិគីមី, និងលាងសម្អាតបន្លែផ្លែឈើយ៉ាងប្រុងប្រយ័ត្នមុននឹងបរិភោគ( មើលជំពូក14 )។ ដោយហេតុថាយើងទំនងជាប្រឈមនឹងសារធាតុពុលក្នុងសហគមន៍ យើងត្រូវតែដាក់សម្ពាធលើរដ្ឋាភិបាលឲ្យបញ្ឈប់សាជីវកម្មពីការបង្កគ្រោះថ្នាក់ដល់ប្រជាជន ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត។
- **រៀបចំសកម្មភាពដើម្បីបង្ការការបំពុលបរិស្ថាន។** ប្រើប្រាស់សកម្មភាពផ្សេងៗដើម្បីបង្ការមហន្តរាយសារធាតុពុល ដែលមានដូចជាការធ្វើបាតុកម្មអត់អាហារ, បាតុកម្មអង្គុយមួយកន្លែង, និងការដើរដង្ហែរក្បួន, ក៏ដូចជាការផ្សព្វផ្សាយតាមរោងកុន, ប្រព័ន្ធព័ត៌មាន, អ៊ីនធឺណែត, និងមធ្យោបាយទំនាក់ទំនងដទៃទៀត ដើម្បីអប់រំប្រជាជន។ ប្រសិនបើរោងចក្រកំពុងបំពុលបរិស្ថាន គួររិះរកមធ្យោបាយដទៃទៀតដែលកម្មករអាចចិញ្ចឹមជីវិតបាន ព្រោះប្រជាជនទាំងអស់ត្រូវការការងារនិងប្រាក់ចំណូល។
- **បង្ខំឲ្យក្រុមហ៊ុនធ្វើការសម្អាត។** ទោះបីចំណុចនេះពិបាកនឹងសម្រេចក៏ដោយ ការទាមទារឲ្យក្រុមហ៊ុននានាធ្វើការសម្អាតសារធាតុពុលដែលរាយប៉ាយ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការតស៊ូទាំងឡាយដើម្បីសិទ្ធិផ្នែកបរិស្ថាន។ បើទោះជាក្រុមហ៊ុនមិនយល់ស្របក៏ដោយ ប្រជាជនទាំងអស់យល់ស្របថាក្រុមហ៊ុនត្រូវតែទទួលខុសត្រូវក្នុងការបង្ការគ្រោះថ្នាក់ និងជួសជុលរាល់ការខូចខាតទាំងឡាយដែលពួកគេបង្ក ឡើង។




- **ដាក់សម្ពាធលើរដ្ឋាភិបាលឲ្យបង្កើនស្តង់ដារសុវត្ថិភាពសម្រាប់ប្រជាជន។** ជាអកុសល រដ្ឋាភិបាលជាច្រើនការពារផលប្រយោជន៍របស់ក្រុមហ៊ុនច្រើនជាងការពារប្រជាជន។ ចំណុចនេះធ្វើឲ្យកាន់តែមានភាពអយុត្តិធម៌ផ្នែកបរិស្ថាន និងឈានទៅរកមហន្តរាយផ្សេងៗនៅពេលដែលក្រុមហ៊ុនមើលឃើញសុវត្ថិភាពប្រជាជន ថាជាការចំណាយដែលអាចចៀសវាងបាន គឺមិនមែនមើលឃើញថាជាការទទួលខុសត្រូវរបស់ខ្លួន។ រដ្ឋាភិបាលទាំងឡាយត្រូវតែផ្លាស់ប្តូរអាទិភាពរបស់ខ្លួនដើម្បីការពារប្រជាជនគ្រប់រូប ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត។
- **ផ្លាស់ប្តូរមធ្យោបាយផលិតរបស់ឧស្សាហកម្ម។** រោងចក្រយូញៀនខាបៃត៍ក្នុងក្រុងបូប៉ាល់ ផលិតថ្នាំសម្លាប់សត្វល្អិតដើម្បីការពារដំណាំពីសត្វល្អិត។ ប៉ុន្តែមានវិធីល្អជាងនេះក្នុងការបញ្ឈប់សត្វល្អិតចង្រៃដោយមិនប្រើសារធាតុគីមី។ ជាការពិត អ្វីៗទាំងអស់សុទ្ធតែមានវិធីរបស់វាដោយបង្កគ្រោះថ្នាក់តិច និងមានស្ថិរភាពខ្ពស់។ ហេតុអ្វីគេអនុញ្ញាតឲ្យឧស្សាហកម្មបំពុលពួកយើង ប៉ុន្តែគេមិនអនុញ្ញាតឲ្យយើងសម្រេចចិត្តអំពីមធ្យោបាយផលិតរបស់អ្វីមួយ ?

# ការប្រឈមគ្រោះថ្នាក់ដែលអាចទទួលបាន? ដើម្បីអ្នកណា?

ជារឿយៗឧស្សាហកម្មនិងរដ្ឋាភិបាលនិយាយដោះសារពីការប្រឈមនឹងការបំផ្លាញបរិស្ថាន (សូម្បីតែមហន្តរាយធ្ងន់ធ្ងរដូចក្រុងបូប៉ាល់) ថាការប្រឈមនឹងគ្រោះថ្នាក់មួយចំនួន អាចទទួលយកបាន គឺដូចជា "ការចំណាយលើការអភិវឌ្ឍន៍" ដែរ។ ជាទូទៅវាមានន័យថា ប្រជាជនដែលងាយរងគ្រោះបំផុតដូចជាពួកយើង ត្រូវបានលះបង់ដើម្បីឲ្យមុខជំនួញក្រុមហ៊ុនមានដំណើរការ។ សម្រាប់ពួកយើងភាគច្រើន គឺមិនអាចទទួលយកបានទេ។ ការស្វែងរកផលប្រយោជន៍ មិនអាចយកមកទូរទាត់នឹងការបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ និងការរំលោភសិទ្ធិក្នុងការទទួលបានសុខភាពល្អនិងបរិស្ថានល្អបានឡើយ។

ប្រសិនបើក្រុមហ៊ុនយូញៀនខាបៃត៍ឬរដ្ឋាភិបាលឥណ្ឌាបានអនុវត្តតាមគោលការណ៍ប្រុងប្រយ័ត្ន(មើលទំព័រ32) នោះប្រហែលជាមហន្តរាយឧស្ម័នពុលក្នុងក្រុងបូប៉ាល់ មិនបានកើតឡើងទេ។

## ការទាមទារឲ្យមានការប្រុងប្រយ័ត្ន

វិធានការសុវត្ថិភាពអាចកាត់បន្ថយគ្រោះថ្នាក់បាន។ ប៉ុន្តែសូម្បីតែវិធានការសុវត្ថិភាពត្រូវបានអនុវត្តក៏ដោយក៏ការប្រឈមគ្រោះថ្នាក់តែងតែមានខ្លះជានិច្ចនៅក្នុងរោងចក្រឧស្សាហកម្ម។ ប្រសិនបើមិនអាចជៀសវាងការប្រឈមគ្រោះថ្នាក់បានទេ យ៉ាងហោចណាស់ក៏គ្រោះថ្នាក់នេះត្រូវបានចែករំលែកស្មើគ្នា និងមិនប៉ះពាល់តែប្រជាជននិងសហគមន៍ក្រីក្រដែរ។

សម្រាប់ពេលយូរអង្វែង ដើម្បីឲ្យមានប្រសិទ្ធភាពបំផុតតាមដែលអាច ឧស្សាហកម្មត្រូវតែបានរៀបចំឡើងក្នុងរបៀបម៉្យាងដែលផ្តល់តម្លៃដល់សុវត្ថិភាពនិងស្ថិរភាព ជាជាងប្រាក់ចំណូលខ្ពស់។ ដើម្បីសម្រេចបញ្ហានេះបាន យើងគួរទាមទារឲ្យសាជីវកម្មទាំងឡាយធ្វើការអភិវឌ្ឍប្រកបដោយសុវត្ថិភាព ហើយរដ្ឋាភិបាលត្រូវធ្វើឲ្យក្រុមហ៊ុនទាំងនោះទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន តាមរយៈការបង្កើតនិងអនុវត្តច្បាប់ដែលការពារសុខភាពនិងបរិស្ថាន។ វិធីមួយក្នុងការលើកកម្ពស់យុត្តិធម៌ផ្នែកបរិស្ថានសម្រាប់មនុស្សគ្រប់គ្នា គឺការទាមទារឲ្យអ្នកដឹកនាំ និងអ្នកមានអំណាចទាំងឡាយ ធ្វើការសម្រេចចិត្តលើបញ្ហាបរិស្ថានដោយផ្អែកលើគោលការណ៍ប្រុងប្រយ័ត្ន។




រោងចក្រដែលបញ្ចេញផ្សែង... ...អាចបង្វិលទៅជាកាំភ្លើង(មូលហេតុនៃមហន្តរាយ)។